# សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោតសម្រេចដាក់ពិន័យអ្នកដែលបំផ្លាញសន្លឹកឆ្នោតដោយការលុបឈ្មោះនិងដកសិទ្ធិឈរឈ្មោះបោះឆ្នោត



រដ្ឋាភិបាលកម្ពុជា បានផ្សព្វផ្សាយសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត នៅថ្ងៃអង្គារនេះ បន្ទាប់ពីច្បាប់នេះត្រូវបានរដ្ឋសភាអនុម័តយកទៅពិនិត្យ និងពិភាក្សាកាលពីថ្ងៃចន្ទ ជាពិសេសច្បាប់នេះបានចែងអំពីទោសទណ្ឌលើអ្នកដែលបំផ្លាញសន្លឹកឆ្នោតយ៉ាងធ្ងន់ធ្ងរ

ដោយការលុបឈ្មោះពីបញ្ជីបោះឆ្នោត និងដកសិទ្ធិឈរឈ្មោះបោះឆ្នោតយ៉ាងតិច ៥ឆ្នាំថែមទៀត។

រដ្ឋាភិបាលកម្ពុជា ផ្សព្វផ្សាយសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោតនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៣ នេះ ដោយកែប្រែទៅលើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រត្រង់មាត្រា២៣ មាត្រា១៤២ និងមាត្រា១៤៣ ចំណែកច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវកែប្រែត្រង់មាត្រា៣៥ មាត្រា១៧១ និងមាត្រា១៧២ ដោយឡែកច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវកែប្រែត្រង់មាត្រា១៣ ខណៈច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវកែប្រែត្រង់មាត្រា១៥។

ច្បាប់ដែលត្រូវធ្វើវិសោធនកម្មនេះ បានកំណត់ថា ពលរដ្ឋខ្មែរដែលមានសិទ្ធិបោះឆ្នោត និងមានបំណងឈរឈ្មោះបោះឆ្នោតជាបេក្ខជនតំណាងរាស្ត្រ ត្រូវអនុវត្តនូវលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ២៣ថ្មី ក្នុងចំណុចទី៤ ដែលតម្រូវឲ្យអនុវត្តសិទ្ធិបោះឆ្នោតដោយបានបោះឆ្នោតសម្រាប់ការបោះឆ្នោតជាសកលចំនួនពីរលើកចុងក្រោយជាប់គ្នាជាដាច់ខាត តែបើអាក់ខានត្រូវតែមានមូលហេតុសមស្រប។

ចំណែកមាត្រា៣៥ថ្មីនៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ និងមាត្រា១៥ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ក៏បានចែងដែលមានខ្លឹមសារដូចគ្នាទៅច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រត្រង់មាត្រា២៣ថ្មី ខាងលើនោះដែរ។

រដ្ឋាភិបាលកម្ពុជា ក៏បានចែងអំពីទោសទណ្ឌត្រង់មាត្រា១៤២ថ្មីថា ត្រូវផាកពិន័យពី ៥លានរៀលទៅ ២០លានរៀលពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយមិនទាន់គិតពីទោសផ្សេងទៀតដល់ជនដែលបានប្រើមធ្យោបាយនានានោះឡើយ ដូចជាការញុះញង់ពលរដ្ឋមិនឲ្យទៅបោះឆ្នោត អុកឡុកការបោះឆ្នោត និងបំផ្លាញសន្លឹកឆ្នោត ជាដើម គឺត្រូវលុបឈ្មោះពីបញ្ជីបោះឆ្នោត និងដកសិទ្ធិឲ្យឈរឈ្មោះបោះឆ្នោតយ៉ាងតិច ៥ឆ្នាំផងដែរ។

ការធ្វើវិសោធនកម្មច្បាប់បោះឆ្នោតនេះ ធ្វើឡើងដោយរងនូវការរិះគន់ពីមជ្ឈដ្ឋានជាតិ និងអន្តរជាតិជាបន្តបន្ទាប់ក្រោមហេតុផលថា ច្បាប់នេះគឺមានបំណងគាបសង្កត់គណបក្សក្រៅរដ្ឋាភិបាលដើម្បីប្រយោជន៍បក្សកាន់អំណាចប៉ុណ្ណោះ។

នាយិកាមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) អ្នកស្រី ចក់ សុភាព សរសេរលើទំព័រហ្វេសប៊ុករបស់ខ្លួននៅថ្ងៃទី២០ មិថុនា នេះថា ការធ្វើ

វិសោធនកម្មច្បាប់បោះឆ្នោតនៅពេលនេះ បានដាក់បន្ទុកធ្ងន់ធ្ងរដោយតម្រូវអ្នកឈរឈ្មោះបោះឆ្នោតត្រូវទៅបោះឆ្នោតជាសកលចំនួនពីរលើកចុងក្រោយជាប់គ្នា លើកលែងករណីមានមូលហេតុសមស្រប។

អ្នកស្រីលើកជាសំណួរថា តើមូលហេតុសមស្រប នឹងត្រូវបានវាយតម្លៃបែបណា? តើការបាត់បង់សិទ្ធិឈរឈ្មោះ តួយ៉ាងដូចជាបក្សភ្លើងទៀន ឬអ្នកនយោបាយដែលត្រូវរងការចោទប្រកាន់ ត្រូវបានដកហូតសិទ្ធិនយោបាយ ជាដើម ឬភៀសខ្លួនដោយសារហេតុផលនយោបាយ នឹងត្រូវថ្លឹងថ្លែងដោយរបៀបណាដែរ?

មន្ត្រីទទួលបន្ទុកសិទ្ធិមនុស្សរូបនេះបញ្ជាក់ថា ជារួម ប្រសិនបើការធ្វើវិសោធនកម្មច្បាប់បោះឆ្នោតនៅពេលនេះក្នុងគោលដៅលើកស្ទួយគោលការណ៍លទ្ធិប្រជាធិបតេយ្យសេរីពហុបក្សមែននោះ គួរចាប់ផ្ដើមពិនិត្យពីលក្ខខណ្ឌស្មុគស្មាញ ដែលបណ្ដាលឱ្យគណបក្សមួយចំនួនត្រូវបាត់បង់សិទ្ធិចូលរួមបោះឆ្នោត និងកែសម្រួលលក្ខខណ្ឌនានាដែលអាចឲ្យអ្នកនយោបាយអាចចូលរួមប្រកួតប្រជែងដោយស្មើភាពគ្នាបាន។

យ៉ាងណាក៏ដោយ កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣ រដ្ឋាភិបាលកម្ពុជាបានចេញលិខិតមួយទៅកាន់ប្រធានរដ្ឋសភា លោក ហេង សំរិន ដោយស្នើសុំពិនិត្យ និងអនុម័តសេចក្ដីព្រាងច្បាប់ស្ដីពីច្បាប់បោះ

ឆ្នោត ដោយចាត់ទុកជាការប្រញាប់ ដើម្បីលើកស្ទួយគុណតម្លៃនៃលទ្ធិប្រជាធិបតេយ្យដែលបានចែងក្នុងរដ្ឋធម្មនុញ្ញ និងដើម្បីលើកកម្ពស់ការទទួលខុសត្រូវរបស់អ្នកនយោបាយទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិផងដែរ។

ទោះជាបែបនេះក្តី ក្រុមអ្នកឃ្លាំមើលសង្គម និងនយោបាយ អះអាងថាការកែច្បាប់បោះឆ្នោតម្តងនេះ គឺមានគោលដៅទុច្ចរិត ក្នុងចេតនាសងសឹក គំនុំនយោបាយ និងបំបែកបំបាក់បំផ្លាញជាតិខ្មែរ ដើម្បីតែអំណាចរបស់គ្រួសារហ៊ុនប៉ុណ្ណោះ ព្រោះខ្លឹមសារនៃច្បាប់នេះបានបង្កប់ចេតនាទុច្ចរិតយ៉ាងច្បាស់ក្រឡែតក្នុងការបោសសម្អាតអ្នកប្រឆាំង និងអ្នកប្រជាធិបតេយ្យពីសមរភូមិនយោបាយនៅកម្ពុជាឱ្យអស់ទៅថ្ងៃក្រោយ៕